# ១៤. ការសម្តែងតួ និងបញ្ជីសំណួរសម្រាប់អ្នកអង្កេត (មេរៀនទី៥)

## ការសម្តែងតួ

អ្នកគឺជាស្ត្រីមានអាយុ៣០ឆ្នាំ (មិនមានផ្ទៃពោះ) និងមិនសូវចេះអក្សរ។ អ្នកបានវិនិច្ឆ័យរោគដោយមានមេរោគអេដស៍កាលពី៧ឆ្នាំកន្លងទៅ។ អ្នកបានប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍រយៈពេល ៣ខែ។ ថ្ងៃនេះអ្នកទៅពិនិត្យមើលជំងឺឱកាសនិយម និងប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ពីព្រោះអ្នកបានបាត់បង់ចំណង់បរិភោគ ចង្អោរ និងពិបាកបរិភោគដោយសារឈឺមាត់។ ក្នុងអំឡុងពេលការទៅគ្លីនិចលើកចុងក្រោយ លោកគ្រូពេទ្យបានប្រាប់អ្នកថា អ្នកត្រូវបរិភោគគ្រប់គ្រាន់ដើម្បីទទួលអត្ថប្រយោជន៍ពីការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍។

អ្នករស់នៅជាមួយស្វាមី និងគ្រួសាររបស់អ្នកនៅតំបន់ដាច់ស្រយាល។ អ្នកមានកូនស្រីមួយ។ នៅក្នុងសួនច្បាររបស់អ្នកអ្នកមានដាំចេកត្រកួនល្ពៅ និងប៉េងប៉ោះ និងចិញ្ចឹមមាន់បីក្បាល។ អ្នកមិនដឹងថាតើអ្នកបានស្រកទម្ងន់ប៉ុន្តែ អ្នកមានអារម្មណ៍ថាអ្នកខ្សោយទៅៗហើយអ្នកដទៃប្រាប់អ្នកថាអ្នកហាក់ដូចជាស្គម និងមានជំងឺ។ អ្នកបានថ្លឹងទម្ងន់ដោយបុគ្គលិកសុខភាព និងទម្ងន់របស់អ្នកគឺ៤៤គីឡូក្រាម និងកម្ពស់១៥៥ សង់ទីម៉ែត្រ។

ប្រភេទអាហាររបស់អ្នកបរិភោគកាលពី ២សប្តាហ៍មុនមាន៖

- អាហាពេលព្រឹក៖ បបរ/ បបរស (កន្លះចានសម្លរ) តែ
- អាហារថ្ងៃត្រង់៖ បាយជាមួយត្រី និងបន្លែ ម្ទេសកាហ្វេពណ៌ខ្មៅ
- អាហារពេលល្ងាច៖ មិនបរិភោគមានអារម្មណ៍ចង់ក្អួត
- អាហារសម្រន់៖ បរិភោគចេក យូរៗម្តង

# បញ្ជីសំណួរសម្រាប់អ្នកអង្កេត

*អំពីបុគ្គលិកសុខាភិបាល/អ្នកធ្វើការសហគមន៍*

តើបុគ្គលិកសុខាភិបាល/អ្នកធ្វើការសហគមន៍បានលើកឡើងនូវប្រធានបទខាងក្រោមនេះទេ?
សូមគូស (✓)។

- ☐ ជំហានទី១– វាយតម្លៃ៖ បានធ្វើការវាយតម្លៃសុខភាព និងអាហារូបត្ថម្ភ
- ☐ ជំហានទី២– វិភាគ៖ រកឃើញបញ្ហា
- ☐ ជំហានទី៣– ស្នើយោបល់៖ ផ្តល់ជម្រើស ឬដំណោះស្រាយឱ្យអតិថិជន
- ☐ ជំហានទី៤– ចរចារ៖ ពិភាក្សាគ្នារកដំណោះស្រាយសម្រាប់កត្តារារាំងចំពោះការអនុវត្ត
- ☐ ជំហានទី៥– តាមដាន៖ ធ្វើផែនការដើម្បីត្រួតពិនិត្យ និងតាមដានជាប្រចាំ ជាបន្តបន្ទាប់

តើមានការវាយតម្លៃអាហារូបត្ថម្ភអ្វីខ្លះ?

______________________________

______________________________

______________________________

- ☐ ការប្រឹក្សាអាហារូបត្ថម្ភធ្វើឡើងដោយផ្អែកលើការវាយតម្លៃសុខភាព និងអាហារូបត្ថម្ភ
- ☐ លើកឡើងអំពីទម្លាប់នៃការបរិភោគ
- ☐ លើកឡើងអំពីស្ថានភាពរបស់អតិថិជន
- ☐ ជម្រុញឱ្យមានអាហារូបត្ថម្ភល្អៗ
- ☐ ផ្តល់ប្រឹក្សាដោយគ្មានការវិនិច្ឆ័យ

តើមានការផ្តល់ប្រឹក្សាអាហារូបត្ថម្ភអ្វីខ្លះ?

______________________________

______________________________

______________________________

☐ បានប្រើប្រាស់ត្រឹមត្រូវនូវប័ណ្ណប្រឹក្សាអំពីការរស់នៅដោយវិជ្ជមាន (សូមគូស ✓)។
សូមបញ្ជាក់នូវប័ណ្ណដែលបានប្រើ៖

______________________________

______________________________

*អំពីអតិថិជន*

តើអតិថិជនបានយល់ពីចំនុចទាំងនេះឬទេ? សូមគូស (✓)។

- ☐ ការបរិភោគប្រកបដោយសុខភាពល្អ
- ☐ ការគ្រប់គ្រងរោគសញ្ញា

យោបល់ផ្សេងៗ

______________________________

______________________________

______________________________